# អង្គរបុរី
## សម្លេងខ្មែរនៅបរទេស

# ការវិភាគ
## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ
## ក្រោមប្រធានបទ កំណាព្យបូរាណខ្មែរអំពីគុណមាតាបិតា

website ៖ www.hoksavann.org

ថ្ងៃទី២២ តុលា ២០០៨



កំណាព្យបូរាណខ្មែរដែលពោលអំពីគុណមាតាបិតា ភាគច្រើនទាក់ទងទៅលើព្រះពុទ្ធសាសនា ព្រោះអ្នកតែងនិពន្ធជាពុទ្ធសាសនិកជន ដូចពាក្យខ្លះតទៅនេះ ៖ ម៉ែឪនៅផ្ទះ លោកទុកជាព្រះ ដូចព្រះឯវត្ត ត្រូវកូនសំពះ ផ្តល់អាហារជូនគាត់ កុំឲ្យលោកអត់ បានបុណ្យច្រើនណាស់ ។ ជាពាក្យណែនាំថា ម្តាយឪពុកទុកដូចជាព្រះនៅក្នុងផ្ទះ គួរកូនប្រុសស្រីគោរពបូជា ដោយជូនបាយទឹកនំចំណីដល់គាត់ នេះជាគុណធម៌ដ៏ល្អរបស់កូន ។ ម៉ែឪមានគុណណាស់ មិនសំពះខ្ចាស់អៀនដៃ ឯអ្នកក្រៅដៃ បែរទៅជាសំពះបាន ។ មានន័យថា អ្នកដទៃអាចលើកដៃសំពះបាន ចំណែកឪពុកម្តាយខ្លួនដែលជាអ្នកមានគុណ បែរជាលើកដៃសំពះមិនបាន ។ ម្តាយឪពុកនិងកូន ប៉ីដូចខ្លួននិងស្រមោល ឃើញខុសកុំដេញចោល កុំថ្កោលទោសអ្នកមានគុណ ។ មានន័យប្រៀបថា ម្តាយឪពុកនិងកូន ដូចស្រមោលនិងខ្លួនឯង គឺមានសាច់ឈាមតែមួយ បើឃើញឪពុកម្តាយធ្វើខុស គួររំលឹកមិនគួរថ្កោលទោសលោកឡើយ ។ ម្លប់ព្រៃព្រឹក្សាត្រជាក់កាយ ម្លប់ឪពុកម្តាយញាតិកា ពិសេសលើសម្លប់ព្រៃព្រឹក្សា ម្លប់គ្រូអាចារ្យប្រសើរលើស ។ ជាពាក្យប្រាប់ថា ឪពុកម្តាយជាម្លប់ជាទីជ្រកកោនរបស់កូនប្រុសស្រី ប្រសើរជាងម្លប់ព្រៃព្រឹក្សាជាទីជ្រកកោននៃអ្នកដំណើរ ។ ឯគ្រូអាចារ្យជាម្លប់នៃសិស្សទាំងឡាយប្រសើរជាងម្លប់មាតាបិតានិងម្លប់ព្រៃព្រឹក្សាទៅទៀតផ្នែកបង្រៀនឲ្យមានបញ្ញាផ្លូវលោកផ្លូវធម៌ ។ ម៉ែឪមានគុណ គុណមានទម្ងន់

ធ្ងន់ដូចប្រឬពី គ្មានអ្វីនឹងសង គុណលោកទាំងពីរ មាសប៉ុនគីរី ថ្លៃពុំស្មើហោង ។ នេះជាការប្រៀបគុណធ្ងន់ដូចផែនដី និងថ្លៃជាងមាស ។ ម្ដាយឪពុកនឹកដល់កូនដូចចង្វាប្រដេញ កូននឹកដល់ម្ដាយឪពុកវិញ ដូចព្រះប្រែក្រោយ ។ ម្ដាយឪពុកនឹកដល់កូនដូចត្រីចង្វា ដែលរត់ឆ្លាចុះឆ្លាឡើង ចំណែកកូននឹកឪពុកម្ដាយវិញ ដូចព្រះប្រែក្រោយ គឺមិនសូវនឹកឡើយ ។ ធម៌អាថ៌ចេះតែភ្លេច ជេរប្រទេចចេះតែចាំ ឪពុកពត់ទៅស្ដាំ អកុសលកម្មទាញទៅឆ្វេង ។ នេះជាពាក្យបន្ទោសរបស់ឪពុកម្ដាយដល់កូនដែលមិនស្ដាប់បង្គាប់ ។ ព្រះពុទ្ធចែកកូនជាបីប្រភេទ គឺអវជាតបុត្រ បុត្រមានវិជ្ជានិងចរិយាអន់ជាងឪពុកម្ដាយ, អនុជាតបុត្រ បុត្រស្មើនឹងឪពុកម្ដាយ, អតិជាតបុត្រ បុត្រខ្ពស់ជាងឪពុកម្ដាយ ដូចបទកាព្យតទៅនេះ ។ អវជាតបុត្រ ខូចបំផុតតាំងពីក្មេង ប្រព្រឹត្តខុសផ្សេងៗ បើលេងអ្វីស្ដីមិនស្ដាប់ ។ មិនស្ដាយជាតិកំណើត ល្ងង់ពីក្មេងដល់ចាស់ស្លាប់ ត្រឹមត្រូវមិនសូវស្ដាប់ ព្រួយគេប្រាប់ទាំងយប់ថ្ងៃ ។ អនុជាតបុត្រ ស្លូតបំផុតស្រណុកប្រើ ប្រកបការប្រសើរ ដើរតែតាមលំអានឪ ។ ប្រដៅទទួលយក ចេះលៃលកស្គាល់ខុសត្រូវ ត្រៀមធ្វើតាមគ្រប់ផ្លូវ មិនសូវភ្លេចដំបូន្មាន ។ អតិជាតបុត្រ ល្អបរិសុទ្ធ ស្គាល់សីលទាន នាំឪទៅនិព្វាន ឈានទៅរកកន្លែងសុខ ។ អវធ្លាក់ចុះក្រោម ប្រព្រឹត្តព្រមតែខាងខុស អតិជាតមារយាទខ្ពស់ អនុនោះយ៉ាងកណ្ដាល ។

អ្នកចេះដឹងខ្មែរសម័យមុននេះបន្តិច ក៏បានពោលអំពីគុណមាតាបិតាជាបទកាកគតិថា ភូមិធម៌ភូមិសុខ ភូមិបុណ្យទៅមុខ កូនរកពុំត្រូវ មិនស្ដាប់វាចា ទេសនាម៉ែឪ តែងចង្អុលផ្លូវ ប្រាប់កូនប្រុសស្រី ។ តែកូនមិនដឹង ច្រើនណាស់តែខឹងនឹងម៉ែឪស្ដី តាមពិតគួរស្ដាប់ សួរស័ព្ទសំដី លោកហើយគប្បី គោរពបូជា ។ ដូចស្ដាប់ព្រះសង្ឃ លំអុតខិនអង្គ បង្គំវន្ទា ព្រះពុទ្ធដាក់ក្បួន ប្រធួននាមា ជាបុព្វចារ្យ លោកគ្រូខាងដើម ។ ពាក្យបុព្វចារ្យដែលប្រែថាអាចារ្យខាងដើមនេះបានដល់មាតាបិតា ដែលបានបង្ហាត់បង្រៀនកូនមុនអាចារ្យទាំងអស់ ។ ព្រះពុទ្ធដាក់ឈ្មោះ បាលីពិរោះ បុព្វទេវា ទេវតាខាងដើម អ្នកផ្ដើមរក្សា បុត្រីបុត្រាហៅទេវតាផ្ទះ ។ គឺម្ដាយឪពុក ជាអ្នកម្ចាស់ស្រុក កូនមិនសំពះ ម៉ែឪទូន្មាន ឈ្លានពានចង់ឈ្នះ សត្រូវនឹងព្រះ កន្លោងអាត្មា ។ ត្រង់នេះ ព្រះពុទ្ធដាក់ឈ្មោះមាតាបិតាជាបុព្វទេវា ប្រែថាទេវតាដើម ។ មុននឹងបន់ស្រន់ទេវតាខាងក្រៅ ត្រូវ

ក្រាបសំពះបន់ទេវតាក្នុងផ្ទះគឺមាតាបិតារបស់ខ្លួនជាមុនសិន ។ ពាក្យដាស់តឿនកូនចៅតទៅទៀតថា ។ អ្នកធ្វើបុណ្យខ្មោច ម៉ែឪស៊ីកើត កំពុងស្រេកឃ្លាន ម៉ែឪរស់នៅ កូនត្រូវធ្វើទាន បំបាត់ក្ដីឃ្លាន ហៅធ្វើបុណ្យខ្មោច ។ ហៅបុណ្យខែភ្លឺ កុំចាំគាត់ឈឺ បរិភោគលែងកើត ជូនគាត់កាលជា ហៅថាបុណ្យខ្មោច គាត់បរិភោគកើត បានជាងរនោច ។ ពាក្យទាំងអស់នេះមានសេចក្ដីថា កូនប្រុសស្រីគួរជូនបាយទឹកនំចំណីដល់គាត់ទាន់គាត់នៅមានជីវិត មិនទាន់ជរាមានជម្ងឺធ្ងន់ ។ កំណាព្យបន្តទៀត ដោយបន្ទោសកូនថា កាលគាត់រស់នៅ ព្រឹកល្ងាចក្ដួលក្ដៅស្រេកឃ្លានអស្ចារ្យ មិនគិតជួយគាត់ ឲ្យអត់អាហារ ឲ្យតែធ្វើការ ចាំផ្ទះឲ្យគេ ។ ចំណីត្រីសាច់ ចង់ស្មើរប្រកាច់ អត់ជូនគាត់ទេ ដល់ឈឺផ្ដេតៗ ម្ដេតៗទើបរេដេកជុះទើបគេ ជូននំចំណី ។ ទាំងជិតទាំងឆ្ងាយ មូលមកសួរម្ដាយ ទាំងប្រុសទាំងស្រី ទុរេននំប៉ុង សម្រាំងថ្មីៗ ម្ដាយឈឺលែងស្ដី រីងផ្កាមស្ងួតក ។ កូនហៅអីម៉ែ ម៉ែស្គាល់ខ្ញុំទេ បានចំណីល្អ ម្ដាយពោលខ្សាវៗ គ្រាវៗឆ្លើយត ថាអើឯងមក៏ ម៉ែអរណាស់ណា ។ កាលម៉ែមិនឈឺ មិនមានជម្ងឺ នោះកូនរាល់គ្នា មិនអាណិតម៉ែ លុះម៉ែជរា ទើបកូនរាល់គ្នា មករុញបញ្ចូល ។ នេះនិយាយពីកូន លុះម្ដាយឪពុកឈឺជិតដាច់ខ្យល់ ទើបមានចិត្តជូននំចំណីដល់គាត់ ។ កាលមានជីវិតនោះកូនគ្មានគិត ម្ដេចរួចវេរា ម៉ែឪទូន្មាន កូនគ្មានបូជា បំពេញសទ្ធា ឲ្យម្ដាយស្នាទាន ។ ស្ដាប់ធម៌ទេសនា ឲ្យម្ដាយជ្រះថា រកសួគ៌និព្វាន ប្រើម្ដាយធ្វើខ្ញុំនៅចាំចង្ក្រាន ឲ្យទៅស្នាទាន ឲ្យឆាប់មកវិញ ។ មើលកូនយកចៅ ខែនេះកូននៅឯកស្ទូងស្រែមិញ ម្ដាយទៅរូតរះ មកផ្ទះចំណេញ ម្ដាយប្រាប់ទៅវិញ អញស្ដាប់លោកទេសន៍ ។ កូនថាស្ទូងហើយ ស្ដាប់ចុះម៉ែអើយ ខែនេះកុំធ្វេស កណ្ដាប់ក្រៀមហែង ម៉ែឯងប្រហែស ដើរស្ដាប់លោកទេសន៍ សំណាបចុកថ្នាល ។ មួយខែបួនសីល គេថាម្ដាយខ្ជិល ពួកកូនត្រកាល ទុកម្ដាយគ្រាន់ប្រើ បំរើធ្ងន់ស្រាល ម្ដាយដួចខួរក្បាល លែងស្គាល់ពុទ្ធដីកា ។ ស្លាប់ទៅជាអុស គេដុតឆេះសុស ហើយគេនាំគ្នា រើសធាតុដាក់ថៅ ភ្នែកស្លោអនិច្ចា ហៅញាតិកា ហែធាតុទៅវត្ត ។ ឲ្យទៅស្ដាប់ធម៌ ឲ្យធាតុត្រេកអរ ព្រោះលែងប្រើគាត់ កាលម្ដាយរស់នៅ មិនឲ្យទៅវត្ត ដុតឆេះខ្លោចម៉ត់ ទើបឲ្យទៅថ្កាន ។ នេះនិយាយអំពីអាកប្បកិរិយារបស់កូនឃាត់ម្ដាយឪពុក មិនឲ្យទៅរក្សាសីលស្ដាប់លោកទេសនា ទុក

គាត់នៅផ្ទះគ្រាន់ប្រើ ។ បន្ទាប់មក មានពាក្យផ្តាស់ផ្តើនថា ។ ហេតុនេះអ្នកអើយ កុំធ្វើព្រងើយ ប្រុសស្រីគ្រប់ប្រាណ បំរើមាតា បិតាកុំខាន ទើបសុខក្សេមក្សាន្ត បានអាយុវ័វែង ។ កុំគប្បីធ្វេស កុំឈ្លោះចចេស នឹងម៉ែឪឯង ជាតិនេះជាតិក្រោយ ទុក្ខសោយមិនលែង ព្រះពុទ្ធសំដែង ច្បាស់ឥតសង្ស័យ ៚

❄ ❄

❄